# I. ឧទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

ព្រះរាជក្រមលេខ ១០ នស ៩៥ ស្តីពីច្បាប់

ថវិការបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ១៩៩៥

ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រា ២៨ និង ៣០ ជំពូកទី២ ស្តីអំពី

ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ ១៩៩៣

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីថវិការបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ប្រចាំឆ្នាំ១៩៩៥ ដែលរដ្ឋសភាបានអនុម័ត ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៤ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# ច្បាប់

## ស្តីពី
## ថវិការបស់រដ្ឋសភា នៃ ព្រះរាជាណាចក្រកម្ពុជា
## ប្រចាំឆ្នាំ ១៩៩៥

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១ -

ថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីទ្រទ្រង់សេវា និង សកម្មភាពទាំងឡាយរបស់តំណាងរាស្ត្រ និង មន្ត្រីរាជការ ទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ។

មាត្រា ២ -

ថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំនិងអនុវត្តដោយអនុលោមទៅតាមមាត្រា ៨១ នៃរដ្ឋធម្មនុញ្ញនិងតាមបទបញ្ញត្តិទាំង ឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុនិងច្បាប់ស្តីពីហិរញ្ញវត្ថុជាធរមាន ។

មាត្រា ៣ -

ចំនួនក្របខ័ណ្ឌមន្ត្រីរាជការអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ត្រូវបានកំណត់សម្រាប់ឆ្នាំ ១៩៩៥ ត្រឹម ២៥០ កន្លែង ។

### ជំពូកទី ២
### ចំណូលនៃថវិការបស់រដ្ឋសភា

មាត្រា ៤ -

ចំណូលសរុប នៃថវិការបស់រដ្ឋសភា បានមកពីឥណទានចំណាយនៃថវិកា ទូទៅរបស់រដ្ឋប្រចាំឆ្នាំ ១៩៩៥ មានចំនួន ទឹក ប្រាក់សរុប ៩០៨០ លានរៀល ។

មាត្រា ៥ -

ចំណូលផ្ទាល់ហេតុរបស់រដ្ឋសភាដែលបានមកពីអំណោយ និង ជំនួយផ្សេងៗ នៅក្នុងឬក្រៅប្រទេស ត្រូវបានចាត់ចែង និង ប្រើប្រាស់ដោយ រដ្ឋសភាខ្លួនផ្ទាល់ ប៉ុន្តែត្រូវធ្វើ ទម្រង់បែបបទបញ្ចូលទៅក្នុងថវិកាជាតិ និង បញ្ចេញមកវិញតាមបទ បញ្ញត្តិ នៃច្បាប់ ។

## ជំពូកទី ៣

## ឥណទានសម្រាប់ចំណាយក្នុងថវិការបស់រដ្ឋសភា

មាត្រា ៦ -

ឥណទានសរុបសម្រាប់ចំណាយក្នុងថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភា មានចំនួន ៩០៨០ លានរៀល ។

មាត្រា ៧ -

ឥណទានដូចមានចែងក្នុងមាត្រា ៦ ខាងលើនេះត្រូវបានផ្តល់សម្រាប់ កិច្ចប្រតិបត្តិការរបស់រដ្ឋសភាស្របតាមជំពូកនានានៃថវិកាជាតិ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ៨ -

ក្រោយពេលចូលជាធរមាន ច្បាប់នេះត្រូវបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ចូលថវិការដ្ឋសភាក្នុងថវិកាជាតិ ប្រចាំឆ្នាំ ១៩៩៥ ។

មាត្រា ៩ -

ច្បាប់នេះត្រូវបានប្រកាសទុកជាការប្រញាប់។ច្បាប់នេះត្រូវបាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ១

ហត្ថលេខា និង ត្រា

ប្រធានរដ្ឋសភាស្តីទី

**លួយ ស៊ីមឈាង**